អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងរាប់ចំនួនសមាជិកគ្រួសារ**

**សិក្សាសង្គម** ៖ បំណិនទំនាក់ទំនង៖ អត្តសញ្ញាណរបស់ខ្លួន៖

**គោលបំណង** ៖ បំណិនសម្បទា៖ រាប់ចំនួនសមាជិកនៅក្នុងគ្រួសារនិងប្រាប់ពីបងប្អូន និងខ្លួនឯងជាកូនទីប៉ុន្មាន?

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់និងយល់លេខតាងនិងការគណនាលេខសាមញ្ញៗ៖

**គោលបំណង** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីចំនួនលេខនិងយល់ន័យពីលេខ ១ដល់៣០ តាមលំដាប់លំដោយឬលើសពីនេះ…។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ដង្កៀបមួយចំនួន ក្រដាសកាតដែលមានរូបចំនួនសមាជិកគ្រួសារ និងមានចំនួនលេខនៅខាងក្រោម (អ្នកអាចទាញយកនៅក្នុងគេហទំព័ររបស់អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារបាន👉https://rermork.org)

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**ការរៀបចំ** ៖ ត្រៀមសម្ភារមួយឈុតសម្រាប់បង្ហាញទៅកាន់កុមារមុនពេលលេងបាន ដើម្បីឱ្យក្មេងៗបានស្គាល់និងបានដឹង។

**សេក្ដីណែនាំ**៖

1. សួរកុមារនូវសំណួរខ្លះទាក់ទងនឹងគ្រួសារ។
   កូនៗស្គាល់ពាក្យថាគ្រួសារអត់? កូនៗមានគ្រួសារអត់? គ្រួសារមានអ្នកណាគេខ្លះ?
2. ឱ្យកុមារឡើងរាប់ចំនួនសមាជិកគ្រួសារនៅក្នុងកាតនោះ
   និងឱ្យកុមារប្រើដង្កៀបគាបលេខឱ្យត្រូវនឹងចំនួនវាជាការស្រេច…។
3. ល្បែងនេះអាចលេងម្ដងម្នាក់បាននិងលេងឱ្យបានគ្រប់គ្នាតែម្ដងកាន់តែល្អ។
4. សម្រាប់កាតអ្នកអាចធ្វើវាចាប់ពីចំនួន១រហូតដល់លេខ១០ ឬពី១០ បានតាមកម្រិតរបស់កុមារដែរ។
5. កាតដែលមាននោះ ត្រូវកាត់វាជាកាតតូចៗ ដែលមានចំនួន៦ក្នុងក្រដាសA4 និងអ៊ុតវាឱ្យបានស្អាត និងរឹងមាំសម្រាប់លេងពេលក្រោយទៀត។
6. ត្រៀមដង្កៀប ឱ្យកុមារម្នាក់១ និងកាតដែលបានធ្វើរួចឱ្យកុមារម្នាក់១ដូចគ្នា។
7. ឱ្យពួកគេមើលថាតើនៅក្នុងកាតរបស់ខ្លួនមានចំនួនប៉ុន្មាន?
   ហើយប្រើដង្កៀបគាបឱ្យចំលេខដែលត្រូវចំនួនសមាជិកគ្រួសារដែលនៅក្នុងកាតនោះជាការស្រេច។

8. នៅពេលដែលកុមារបានគាបរួចហើយ អ្នកអាចធ្វើការបង្ហាញពីការគាបរបស់ពួកគេនៅលើក្តារខៀនបានប្រសិនបើមានពេលគ្រប់គ្រាន់។
9. ប្រសិនបើអាច ឬកុមារមានសមត្ថភាពខ្ពស់និងមានពេល អាចឱ្យក្មេងប្រាប់ពីរូបភាពក្នុងកាតបានថាជាអ្នកណាខ្លះ។
10. ប្រសិនបើពួកគេអាចប្រាប់បានមានន័យថា ពួកគេស្គាល់បានច្រើន។